MRLG
MEKONG REGION
LAND GOVERNANCE

DISCUSSION NOTE

# ការអនុវត្តបទដ្ឋាននៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) នៅក្នុងប្រទេសកម្ពុជា

May 2019

ដោយលោក Florian Rock

វត្ថុបំណងនៃឯកសារអំពីការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (Free, Prior, and Informed Consent “FPIC”) នេះ គឺផ្តល់នូវសេចក្តីសង្ខេបអំពីរបៀបនៃការអនុវត្តនីតិវិធីពិគ្រោះយោបល់នឹង FPIC ដែលរឹងមាំនៅក្នុងការអនុវត្តជាក់ស្តែងនៅកម្ពុជានៅក្នុងវិស័យនិងសកម្មភាពនានា។ ឯកសារនេះមានគោលបំណងបង្ហាញថា គេអាចអនុវត្ត FPIC ទៅតាមកាលៈទេសៈខុសៗគ្នា និងថា ការអនុវត្តបទដ្ឋាន FPIC នេះអាចនាំទៅរកភាពប្រសើរឡើងជាទូទៅនៃការប្រាស្រ័យទាក់ទងគ្នានិងការយោគយល់គ្នារវាងស្ថាប័នរដ្ឋាភិបាល វិនិយោគិនឯកជន និងសហគមន៍ពាក់ព័ន្ធ។

## តើ FPIC ជាអ្វី?

គោលគំនិតនៃការយល់ព្រមជាមុនដោយសេរីនិងបន្ទាប់ពីទទួលបាន ព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) គឺជាបទដ្ឋានទទួលទទួលស្គាល់ដោយអន្តរជាតិដែលអនុវត្តទៅការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច។ គោលគំនិតនេះត្រូវគេចាត់ទុកយ៉ាងទូលំទូលាយថាជាវិធីល្អបំផុតសម្រាប់ការប្រមែប្រមូលទស្សនៈរបស់ជនជាតិដើមភាគតិចពាក់ព័ន្ធនឹងសកម្មភាពនានាដែលប៉ះពាល់ដល់ពួកគេនិងដីធ្លីរបស់ពួកគេ និងដើម្បីការធានាថាសិទ្ធរបស់ពួកគេត្រូវបានគោរព។ គោលការណ៍នេះតម្រូវឱ្យក្រុមហ៊ុននិងរដ្ឋបាលនានាចូលរួមក្នុងកិច្ចពិគ្រោះយោបល់ដែលមានអត្ថន័យជាមួយនឹងសហគមន៍ជនជាតិដើមដែលអាច នឹងរងផលប៉ះពាល់អវិជ្ជមានពីធុរកិច្ចឬគម្រោងអភិវឌ្ឍន៍ប្រភេទណាមួយឬការការពារការប្រើប្រាស់ធនធានដោយបង្កលក្ខណៈឱ្យមានការចូលរួមទាំងនៅក្នុងដំណើរការនិងលទ្ធផល។ FPIC គឺជាបទដ្ឋានមួយដែលការពារនៅក្រោមអនុសញ្ញា ILO លេខ ១៦៩ និងសេចក្តីថ្លែងការអង្គការសហប្រជាជាតិស្តីពីសិទ្ធរបស់ប្រជាជនជនជាតិដើមភាគតិច (UNDRIP) ដែលកម្ពុជាក៏ជាហត្ថលេខីមួយផងដែរ។

‘ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ’ (FPIC) គឺជាគោលការណ៍មួយដែលកំណត់គឺជាគោលការណ៍មួយ ដែលកំណត់ ថាសហគមន៍មានសិទ្ធផ្តល់ឬមិនផ្តល់ការយល់ព្រមរបស់ខ្លួនចំពោះគម្រោងស្នើឡើងនានាដែលអាចនឹងប៉ះពាល់ដល់ដីធ្លីដែលពួកគេកាន់កាប់អាស្រ័យឬប្រើប្រាស់ជាប្រពៃណី។

បច្ចុប្បន្ន FPIC គឺជាគោលការណ៍សំខាន់មួយនៅក្នុងច្បាប់និងយុត្តិសាស្រ្តអន្តរជាតិដែលទាក់ទង នឹងប្រជាជនជនជាតិដើមភាគតិចហើយកាន់តែត្រូវបានស្ថាប័នផ្តល់វិញ្ញាបនបត្រ វិទ្យាស្ថានហិរញ្ញប្បទាន និងធនាគារ អន្តរជាតិ ព្រមទាំងសមាគមន៍ឧស្សាហកម្ម (ឧទាហរណ៍ ក្រុមហ៊ុនវិស័យរុករករ៉ែ) ទទួលយកកាន់តែច្រើនឡើងៗធ្វើជាវិធានគាំពារនិងជាបទដ្ឋាន។

ទោះបីជាគោលគំនិត FPIC កកើតឡើងជាដំបូងពាក់ព័ន្ធនឹងជនជាតិដើមភាគតិចនិងដែនដីរបស់ពួកគេក្តីជាគោលការណ៍វាជាវិធានគាំពារផ្នែកសង្គមដែលគោរពដល់សិទ្ធរបស់សហគមន៍ទាំងឡាយដែលជីវភាពរបស់ខ្លួននឹងត្រូវរងផលប៉ះពាល់ដោយសារការគំនិតផ្តួចផ្តើមពីខាងក្រៅ ឬដែលរងឥទ្ធិពលដោយសារផលប្រយោជន៍ពីខាងក្រៅ។ គោលការណ៍នេះអនុវត្តចំពោះការអភិវឌ្ឍទាំងឡាយណាដែលផ្លាស់ប្តូរសិទ្ធកាន់កាប់ដីធ្លីការប្រើប្រាស់ដីធ្លីឬបរចិញ្ចឹមជីវិតរបស់ប្រជាជនមូលដ្ឋានហើយមិនមែនអនុវត្តចំពោះតែវិធានការកាត់បន្ថយផលប៉ះពាល់ដែលអាចកើតឡើងដែលស្នើឡើងដោយគម្រោងវិនិយោគប៉ុណ្ណោះនោះទេ។ នៅក្នុងការអនុវត្តជាក់ស្តែង គម្រោង ឬសកម្មភាពណាមួយក៏ដោយដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចក្តីនិងសហគមន៍មិនមែនជនជាតិដើមភាគតិចក្តីមិនមែនជាការរឹតត្បិតការអនុវត្តបទដ្ឋាន FPIC តែចំពោះសហគមន៍ជនជាតិភាគតិចប៉ុណ្ណោះនោះឡើយ។

FPIC ជាធាតុចាំបាច់ដើម្បីធានាភាពស្មើភាពគ្នារវាងសហគមន៍និងរដ្ឋាភិបាលឬក្រុមហ៊ុន។ ហើយនៅទីណាដែលមានការព្រមព្រៀងគ្នាដែលកើតចេញពីការចរចា FPICផ្តល់ដល់ក្រុមហ៊ុននូវការវិនិយោគដែលមានសន្តិសុខខ្ពស់និងមានហានិភ័យតិច។ FPICក៏ពាក់ព័ន្ធនឹងការវាយតម្លៃផលប៉ះពាល់ដោយប្រយ័ត្នប្រយែង និងដោយមានការចូលរួមកិច្ចព្រមព្រៀងស្តីពីរចនាបថគម្រោងនិងកិច្ចព្រមព្រៀងបែងចែកផលប្រយោជន៍ផងដែរ។

គោលគំនិត FPIC អាចពន្យល់ដូចខាងក្រោម ៖
FPIC រួមបញ្ចូលនូវសិទ្ធរបស់ប្រជាជនជនជាតិដើមភាគតិចក្នុងការយល់ព្រម ឬបដិសេធសំណើអភិវឌ្ឍន៍នៅលើដីធ្លីរបស់ពួកគេដោយផ្អែកលើគោលការណ៍ដូចតទៅ ៖



*PA rangers, community representatives and WCS staff discussing PA zoning on the ground in Kulen Promtep Wildlife Sanctuary. Photo credit: WCS*

**ដោយសេរី៖** គ្មានការបង្ខិតបង្ខំ ការបំភិតបំភ័យ ឬការបន្លំ។ គោលការណ៍ជាមូលដ្ឋាននៃច្បាប់កិច្ចសន្យាគឺថាភាគីនីមួយៗ ត្រូវផ្តល់ការយល់ព្រមដោយសេរីនិងពិតឥតក្លែងក្លាយក្នុងការ ជាប់កាតព្វកិច្ចនៃកិច្ចសន្យាដោយគ្មាន ការរងនូវឥទ្ធិពល មិនត្រឹមត្រូវការ បង្ខិតបង្ខំ ការបំភិតបំភ័យ ឬការបន្លំ។

**ជាមុន៖** ការយល់ព្រមត្រូវតែធ្វើឡើងក្នុងពេលវេលាគ្រប់គ្រាន់ នៅមុនការអនុញ្ញាតណាមួយឬការចាប់ផ្តើមនៃសកម្មភាពនានា។ គេត្រូវតែផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ដំណើរការពិគ្រោះយោបល់ដោយសុទ្ធចិត្តឱ្យប្រព្រឹត្តទៅស្របតាមនីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្ត។

ដើម្បីឱ្យការផ្តល់ឬមិនផ្តល់ការយល់ព្រមមានអត្ថន័យត្រឹមត្រូវ គេត្រូវតែធ្វើការសម្រេចចិត្តនៅមុនការធ្វើសេចក្តីសម្រេចចិត្តផ្លូវការ (ដូចជា ដោយរដ្ឋាភិបាល) អំពីថាតើគេគួរតែអនុញ្ញាតឲ្យឱ្យការអភិវឌ្ឍមួយដែលស្នើឡើងអាចដំណើរការទៅមុខកើតដែរឬយ៉ាងណា។

**ដោយទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ៖**ប្រជាជនជនជាតិដើមភាគតិចគួរតែទទួលបានព័ត៌មានជាទីពេញចិត្តនិងគ្រប់ជ្រុងជ្រោយទាក់ទងនឹងគម្រោងក្នុងនោះរួមទាំងការវាយតម្លៃបឋមអំពីផលប៉ះពាល់សេដ្ឋកិច្ច សង្គមវប្បធម៌ និងបរិស្ថានរបស់គម្រោងនោះផងដែរ។ អ្វីដែលសំខាន់បំផុតគឺថាព័ត៌មាននេះត្រូវតែងាយស្រួលយល់បានចំពោះប្រជាជនដែលពាក់ព័ន្ធនិងភាពត្រឹមត្រូវ។ ចំពោះចំពោះគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចរាល់ផែនការ និងសំណើទាំងអស់ដែលផ្តល់ព័ត៌មានលម្អិតអំពីគម្រោងពេលវេលាវិសាលភាព ទីតាំង ផែនការកាត់បន្ថយផលប៉ះពាល់ និងព័ត៌មានសំខាន់ៗផ្សេងទៀត (ដូចជា ព័ត៌មានដែលមាននៅក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ត្រូវតែចែករំលែកជាមួយសហគមន៍ជនជាតិដើមភាគតិចនៅមុនពេលសេចក្តីសម្រេចចិត្តណាមួយនឹងត្រូវធ្វើឡើង ដើម្បីផ្តល់ឬមិនផ្តល់ការយល់ព្រមចំពោះគម្រោងនោះ។

**ការយល់ព្រម៖** ដំណើរការមួយដែលដាក់ការពិគ្រោះយោបល់និងការចូលរួមជាធាតុសំខាន់។

ដំណើរការនេះតម្រូវឱ្យរដ្ឋ ក្រុមហ៊ុន ឬអាជ្ញាធរមូលដ្ឋានធ្វើការចរចាដោយភាពស្មោះត្រង់ជាមួយតំណាងស្របច្បាប់របស់ប្រជាជនជនជាតិដើមភាគតិចដើម្បីទទួលបានការយល់ព្រមជាមុនដោយគ្មានការបង្ខិតបង្ខំនិងបន្ទាប់ពីបានទទួលព័ត៌មានគ្រប់ជ្រុងដោយពីពួកគេពាក់ព័ន្ធ នឹងការប្រើប្រាស់ដីធ្លីឬធនធានរបស់ពួកគេ និងដើម្បីផ្តល់សំណងដល់ផលប៉ះពាល់អវិជ្ជមានណាមួយដែលកើតឡើងជាផលវិបាកនៃគម្រោងអភិវឌ្ឍន៍នោះទៅលើជនជាតិដើមភាគតិច។

## FPIC នៅក្នុងច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា

នៅក្នុងប្រទេសកម្ពុជា មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ « ព្រះរាជាណាចក្រកម្ពុជាចែងថាព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិសេចក្តីថ្លែងការសាកលស្តីពីសិទ្ធមនុស្សកតិកាសញ្ញានិងអនុសញ្ញាទាក់ទិននឹងសិទ្ធមនុស្ស សិទ្ធស្ត្រីនិងសិទ្ធកុមារ»។ ជាងនេះទៅទៀត យោងតាមមាត្រា ៣៥៖ «ពលរដ្ឋខ្មែរទាំងពីរភេទត្រូវបានផ្តល់សិទ្ធឱ្យចូលរួមសកម្មនៅក្នុងក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រទេសជាតិ»។

ខណៈដែលកម្ពុជាមិនទាន់បានផ្តល់សច្ចាប័នដល់អនុសញ្ញា ILO លេខ១៦៩ នៅឡើយក្តី រាជរដ្ឋាភិបាលកម្ពុជា (RGC) បានអនុម័ត UNDRIP រួចហើយ ហើយចាំបាច់ត្រូវផ្តល់ការយកចិត្តទុកដាក់ពាក់ព័ន្ធទៅលើ FPIC ជាផ្នែកមួយនៃទំនួលខុសត្រូវសង្គមរបស់សាជីវកម្មនិងការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធមនុស្ស។

នៅក្នុងសកម្មភាពគម្រោងដែលទាក់ទងនឹង REDD+ ទាំងឡាយ FPIC ត្រូវបានបញ្ញត្តថាជាវិធានគាំពារក្នុងចំណោមវិធានគាំពារសំខាន់ៗនឹងបានក្លាយជាលក្ខខណ្ឌតម្រូវមួយសម្រាប់ការផ្តល់វិញ្ញាបនបត្របញ្ជាក់ដោយបទដ្ឋានអន្តរជាតិ (ឧ. VCS និង CCB)។ ហើយនេះគឺបុរេលក្ខខណ្ឌសម្រាប់ការចូលទៅទីផ្សារកាបូនពិភពលោក។ សិទ្ធទទួលបានគោលការណ៍ FPIC នេះអនុវត្តចំពោះកិច្ចពិភាក្សា REDD+ ពាក់ព័ន្ធនឹងការផ្លាស់ប្តូរជា

1.វិធានការការពារ ក្រុងកង់គូន នៅក្រោម UNFCCC https://redd.unfccc.int/fact-sheets/safeguards.html (ការគោរពចំណេះដឹងនិងសិទ្ធរបស់ជនជាតិដើមភាគតិចនិងសមាជិកសហគមន៍មូលដ្ឋាន ដោយពិចារណាទៅលើកាតព្វកិច្ចអន្តរជាតិពាក់ព័ន្ធ កាលៈទេសៈនិងច្បាប់ជាតិ និងដោយកត់សម្គាល់ថា មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីថ្លែងការណ៍អង្គការសហប្រជាជាតិស្តីពីសិទ្ធរបស់ជនជាតិដើមភាគតិច)។

សក្តានុពលនៃការប្រើប្រាស់ធនធានដែលអាចប៉ះពាល់ដល់របរចិញ្ចឹមជីវិតរបស់សហគមន៍ជនជាតិដើមភាគតិចនិងសហគមន៍ដទៃទៀតដែលរស់ពឹងផ្អែកលើព្រៃឈើ។

គោលការណ៍ណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចសិទ្ធកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ (VGGT) របស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិដែលជាបទដ្ឋានអន្តរជាតិដ៏សំខាន់មួយផ្តល់អនុសាសន៍ថានៅទីណាដែលគម្រោងមួយអាចនឹងប៉ះពាល់ដល់ធនធានដែលសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធទៅលើធនធានទាំងនោះ គេ«គួរតែផ្អែកទៅលើកិច្ចពិគ្រោះយោបល់ដែលមានប្រសិទ្ធភាពនិងមានអត្ថន័យជាមួយនឹងជនជាតិដើមភាគតិចតាមរយៈស្ថាប័នតំណាងផ្ទាល់ខ្លួនរបស់ពួកគេដើម្បីទទួលបានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ពួកគេ។

អនុសញ្ញាស្តីពីជីវសាស្រ្តចម្រុះ (ឆ្នាំ ២០១៧) គឺជាលិខិតតូបករណ៍មួយផ្សេងទៀតដែលជំរុញការអនុវត្ត FPIC និងត្រូវបានចុះហត្ថលេខានិងផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា។

ក្រសួងបរិស្ថាន (MoE) កំពុងស្ថិតក្នុងដំណើរការបញ្ចប់ជាស្ថាពរនូវក្រមបរិស្ថាន និងធនធានធម្មជាតិថ្មីរបស់ប្រទេសកម្ពុជា។ ក្រមនេះនឹងដាក់បញ្ចូលនូវបទប្បញ្ញត្តិស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ការកំណត់និងបែងចែកតំបន់នៃតំបន់ការពារធម្មជាតិ( PA ) និងការរៀបចំការគ្រប់គ្រងរួមគ្នាដែលទាំងបីផ្នែកនេះមាននិយាយយោងអំពីដំណើរការ FPIC និងដំណើរការពិគ្រោះយោបល់។កន្លងមកពុំទាន់មានគោលការណ៍ណែនាំថ្នាក់ជាតិឬថ្នាក់ក្រោមជាតិស្តីពី FPIC សម្រាប់ប្រទេសកម្ពុជានៅឡើយទេ។ ប៉ុន្តែ សកម្មភាពកសាងសមត្ថភាពសំខាន់ៗត្រូវបានធ្វើឡើងដើម្បីកសាងការយល់ដឹងរបស់សង្គមស៊ីវិលនៅថ្នាក់ជាតិនិងនៅថ្នាក់តំបន់អំពីសិទ្ធ FPIC ជាពិសេសសកម្មភាពដែលអនុវត្តដោយអង្គការ Oxfam Australia។ មគ្គុទ្ទេសក៍ស្តីពី FPIC ដែលផលិតដោយអង្គការ Oxfam កាលពីឆ្នាំ ២០១០ ត្រូវបានបកប្រែជាភាសាខ្មែររួចជាស្រេចហើយ។ នៅក្នុងបរិបទនៃការពិគ្រោះយោបល់និងការតាមដាន REDD+ ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលដូចជា WCS ឬ CLEC សុទ្ធតែទទួលបានសមត្ថភាពនិងចំណេះដឹងសំខាន់ៗអំពី FPIC។

## ករណីសិក្សាចំនួនបួនទាក់ទងនឹងការអនុវត្តបទដ្ឋាន FPIC

### **១**) **គម្រោង** REDD+ **នៅដែនជម្រកសត្វព្រៃកែវសីមាដែលអនុវត្តដោយ** WCS

គម្រោង REDD+ សាក ល្បងនៅតំបន់ព្រៃការពារសីមា (បច្ចុប្បន្នហៅថាដែនជម្រកសត្វព្រៃកែវសីមា) ត្រូវបានផ្តួចផ្តើមឡើងកាលពីខែមករាឆ្នាំ ២០១០ ដោយអង្គការអភិរក្សសត្វព្រៃ (WCS) និងរដ្ឋបាលព្រៃឈើជាដៃគូគម្រោង។ គម្រោងនេះមានបំណងគាំទ្រដល់ការការពារព្រៃចំណាស់នៅក្នុងតំបន់ស្នូលទំហំ ១៦៦.៩៨៣ ហិកតា នៅក្នុងតំបន់ព្រៃការពារសីមា នៅខេត្តមណ្ឌលគិរីដែលស្ថិតនៅភាគឦសាននៃប្រទេស កម្ពុជា។ សីមាគឺជាគម្រោង REDD+ បង្ហាញជាផ្លូវការដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជានិងផ្តោតគោលដៅទៅលើទីផ្សារកាបូនស្ម័គ្រចិត្ត។ រាជរដ្ឋាភិបាលកម្ពុជាគឺជាអ្នកស្នើគម្រោងនិងជាម្ចាស់កាបូន។

តម្រូវការឱ្យមាន FPIC ត្រូវបានជំរុញដោយគោលការណ៍អន្តរជាតិ (ឧ. សេចក្តីថ្លែងការណ៍អង្គការសហប្រជាជាតិស្តីពីសិទ្ធជនជាតិដើមភាគ តិច (UNDRP) និងគោលការណ៍ណែនាំទាក់ទិននឹង REDD+។ ដើម្បីលម្អិតឯកសារគម្រោងសម្រាប់ REDD+ និងដើម្បីអនុលោមតាម បទដ្ឋានអន្តរជាតិ WCS បានសម្រេចចិត្តអនុវត្ត FPIC នៅក្នុងគ្រប់ភូមិដែលចូលរួម ដែលនេះជាដំណើរការមួយដែលរួមមានទាំងការពិគ្រោះយោបល់និងការចរចាជាច្រើនលើកច្រើនសានៅចន្លោះពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៣។

វិធីសាស្រ្ត FPIC ពេញលេញត្រូ វបានអនុវត្តនៅក្នុងភូមិទាំង ២០ ដែលប្រើប្រាស់តំបន់កាត់ទុកសម្រាប់ REDD+ ជាទៀងទាត់ដោយមិនគិត អំពីថាតើភូមិ ទាំ ងនេះជាភូមិជនជាតិដើមភាគតិចដែលបានចុះបញ្ជីឬអត់ (សហគមន៍ព្នង ១២ សហគមន៍ សហគមន៍ស្មៀង ១សហគមន៍) ភូមិចម្រុះ ឬភូមិមិនមែនជនជាតិដើមភាគតិច។ នៅតំបន់នេះ គេឃើញមានការហូរចូលយ៉ាងគំហុកនូវប្រជាជនខ្មែរចំណាកស្រុកមកពីតំបន់ ខាងក្រោមដែលស្វែងរកដីធ្លីនិងឱកាសការងារ។ FPIC រួមមានការងារជា ៣ ជំហាន នៅក្នុងភូមិនីមួយៗដែលត្រូវចុះទៅទស្សនកិច្ចដាច់ដោយឡែកៗពីគ្នា ៖

| | |
|---|---|
| ជំហានទី១ | ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនមូលដ្ឋាន ការពិភាក្សាអំពីផលប៉ះពាល់ជាសក្តានុពលរបស់គម្រោងការពិគ្រោះយោបល់អំពីការរៀបចំផែនការគម្រោង។<br>ថ្ងៃទី១ - ការលើកកម្ពស់ការយល់ដឹង ការវាយតម្លៃផលប៉ះពាល់ជាមួយមេភូមិ/គណៈកម្មាធិការភូមិ។<br>ថ្ងៃទី២ - កិច្ចពិភាក្សាពេញអង្គជាមួយសមាជិកសហគមន៍គ្រប់រូប។ |
| ជំហានទី២ | កិច្ចពិភាក្សាអំពីការយល់ព្រម និងការធ្វើបទបង្ហាញអំពីកិច្ចព្រមព្រៀងសហគមន៍ដែលបានស្នើឡើង ក្នុងនោះរួមបញ្ចូលទាំងការណែនាំផ្នែកច្បាប់ឯករាជ្យដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកឈ្មោះអង្គការ CLEC |
| ជំហានទី៣ | ការពិនិត្យសម្រេចនិងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើនិងភូមិដែលពាក់ព័ន្ធ។ |

សិទ្ធកាន់កាប់ដីធ្លីត្រូវបានបញ្ជាក់បំភ្លឺជូនដល់សហគមន៍ IP ជាច្រើនក្នុងទម្រង់ជាប័ណ្ណកម្មសិទ្ធដីរួម។ ក្នុងអំឡុងឆ្នាំ២០១២ អ្នកភូមិមួយចំនួនបានទទួលកម្មសិទ្ធដីឯកជនដែលចេញឱ្យតាមសារាចរណែនាំលេខ ០១ ដោយផ្នែកខ្លះនៃដីទាំងនេះមានទីតាំងស្ថិតនៅក្នុងតំបន់ព្រៃការពារ។

វិធីសាស្ត្រ FPIC នៅក្នុងដែនជម្រកសត្វព្រៃកែវសីមាបានឈានទៅដល់ការចុះហត្ថលេខាលើបែបបទយល់ព្រមនៅកម្រិតភូមិហើយចុងក្រោយបង្អស់បានឈានដល់ការសម្រេចបាននូវ «ការយល់ព្រមអនុវត្តកម្មវិធី REDD» នៅកម្រិតគ្រួសារតាមរយៈបែបបទតាមរយៈបែបបទយល់ព្រមដែលផ្តិតមេដៃកាលពីចុងឆ្នាំ ២០០២។ កិច្ចព្រមព្រៀងថ្នាក់ភូមិត្រូវបានចុះហត្ថលេខាដោយមេភូមិ មេឃុំ និងប្រធានគណៈកម្មាធិការសហគមន៍ នៅឯពិធីចុះហត្ថលេខា FPIC ផ្លូវការមួយជាមួយរដ្ឋបាលព្រៃឈើកាលពីខែមករា ឆ្នាំ២០១៣។ តំបន់ព្រៃការពារ សីមា បានទទួលការទទួលស្គាល់ជាពិសេសដោយសារការយកចិត្តទុកដាក់របស់ខ្លួនចំពោះការអនុវត្ត FPIC នៅក្នុងគ្រប់ភូមិទាំងអស់ដែលពាក់ព័ន្ធ។ តំបន់នេះផ្តល់ជាគំរូមុនដំបូងគេបង្អស់នៃការអនុវត្ត FPIC នៅក្នុងប្រទេសកម្ពុជាដែលអនុលោមទៅតាមគោលការណ៍ណែនាំអន្តរជាតិ។ សីម៉ា គឺជាគម្រោង REDD+ សហគមន៍មុនដំបូងគេនៅក្នុងតំបន់អាស៊ីដែលបានទទួលការផ្តល់សុពលភាពរួមគ្នា និងការបញ្ជាក់ដោយស្ថាប័នបទដ្ឋានបញ្ជាក់កាបូន (VCS) និងបទដ្ឋានអាកាសធាតុសហគមន៍ជីវចម្រុះ (CCB) (សុពលភាពមាស) នៅឆ្នាំ២០១៥។ នៅក្នុងឆ្នាំ២០១៦ តំបន់ព្រៃការពារ សីមា ត្រូវបានប្រែក្លាយទៅជាដែនជម្រក សត្វព្រៃ កែវសីមា និងបានផ្ទេរពីដែនសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន (MoE)។

នៅឆ្នាំ ២០១២ នៅពេលដែល FPIC ត្រូវបានអនុវត្តនៅក្នុងភូមិទាំង ២០ ពេលនោះមិនទាន់មានប្រព័ន្ធបែងចែកផលប្រយោជន៍នៅឡើយទេ។ ក្រោយមករាជរដ្ឋាភិបាលកម្ពុជាក៏បានយល់ព្រមថា សហគមន៍ដែលចូលរួមនឹងទទួលបានយ៉ាងហោចណាស់ ៥0% នៃចំណូលសុទ្ធ បន្ទាប់ពីទូទាត់រាល់ការចំណាយសព្វគ្រប់រួចរាល់។ ជាចុងក្រោយ ការបែងចែកផលប្រយោជន៍ត្រូវបាន សម្រេចសម្រាប់ឆ្នាំ ២០១៧-២០១៨ ដោយគ្របដណ្តប់ការចំណាយលើតម្រូវការអភិវឌ្ឍន៍របស់សហគមន៍ ការបែងចែកមូលនិធិ និងការគ្រប់គ្រងសម្រាប់ការបែងចែកផលប្រយោជន៍ពីកម្មវិធី REDD+។ ភូមិចំនួន ២០ នឹងទទួលបានប្រាក់ចំនួនប្រហែល ១១.៧00ដុល្លារអាមេរិកក្នុងមួយភូមិជាប្រាក់បើកលើកទីមួយនៅឆ្នាំ ២០១៩ (បើកឱ្យទាំងអស់តែម្តង)។

គម្រោងដដែលនេះក៏អនុវត្តផងដែរ នូវយន្តការសារទុក្ខដែលអនុញ្ញាតឱ្យគេអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់ក្រុមអនុវត្តគម្រោងព្រមទាំងលេខទូរស័ព្ទទំនាក់ទំនងពិសេស /ប្រអប់ដាក់ពាក្យបណ្តឹង ដើម្បីធ្វើការពិនិត្យ វាយតម្លៃ និងដោះស្រាយ។ បន្ថែមលើនេះក្រុមប្រឹក្សាឃុំដែលមានស្រាប់ដែលមានសមត្ថកិច្ចលើគម្រោងត្រូវបានកំណត់ឱ្យដើរតួនាទីជាភាគីទីបីក្នុងការទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋនៅក្នុង ឃុំរបស់ខ្លួន និងណែនាំប្រជាពលរដ្ឋឱ្យទៅរកអាជ្ញាធរសមស្រប ឬដោះស្រាយទាំងនោះដោយផ្ទាល់ដោយជារឿយៗតាមរយៈការសម្រុះសម្រួលរវាងភាគីដែលរងផលប៉ះពាល់។

## មេរៀនពីគម្រោង REDD+ នៅដែនជម្រកសត្វព្រៃកែវសីមា

- ការអនុវត្ត FPIC បានផ្តល់ជាគំរូនាំមុខនៃតម្លាភាពនិងភាពត្រឹមត្រូវដែលក៏អាចអនុវត្តផងដែរចំពោះគម្រោងដទៃទៀតនិងក្នុងវិស័យព្រៃឈើ កសិកម្ម និងរ៉ែដោយទាំងវិស័យឯកជននឹងទាំងតួអង្គរដ្ឋ។ ដំណើរការជាច្រើនដែលប្រើប្រាស់នៅតំបន់ សីមា អាចយកទៅចម្លងសម្រាប់ការអនុវត្តនៅកន្លែងផ្សេងទៀតបាន។
- អ្វីដែលសំខាន់ គឺត្រូវកត់សម្គាល់ថាសហគមន៍ចុះហត្ថលេខាលើ កិច្ចព្រមព្រៀងក៏ព្រោះតែពួកគេរំពឹងបានផលប្រយោជន៍ វិជ្ជមានសម្រាប់ជីវភាពរស់នៅពីគម្រោង REDD+ និងដោយសារពួកគេទុកចិត្តអង្គការ WCS ជាដៃគូយូរអង្វែង និងការសម្រេចចិត្តរបស់មេដឹកនាំសហគមន៍។ ទោះបីយ៉ាងនេះក្តី គេអាចចាត់ទុកថាជាជោគជ័យបានហើយនៅពេលគេទទួលបានការយល់ព្រមពេញលេញ សម្រាប់គម្រោងនេះពីសំណាក់គ្រប់ភូមិទាំងអស់។

- ជាសំខាន់ គេត្រូវធានានូវសិទ្ធប្រពៃណីរបស់ IP និងសហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ព្រៃឈើ និងដីកសិកម្មដែលមានស្រាប់។
- ការអនុវត្ត FPIC ពេញលេញនៅតាមភូមិដាច់ស្រយាលអាចជាដំណើរការមួយដែលស៊ីពេលវេលាវែងនិងអស់ការចំណាយច្រើន។ ដំណើរការបែបនេះបានចំណាយពេលអស់ជិត ២ ឆ្នាំ នៅក្នុងភូមិទាំង ២០ និងពាក់ព័ន្ធនឹងថវិការមូលនិធិម្ចាស់ជំនួយដ៏ច្រើនគួរសម។ ប៉ុន្តែការចំណាយនេះអាចនឹងទូទាត់សងវិញបានខ្លះតាមរយៈផលប្រយោជន៍នាពេលអនាគតពីគម្រោង REDD+។
- អ្នកភូមិប្រទះការលំបាកមួយចំនួនក្នុងការព្យាយាមបង្កើតឱ្យមានជម្រើសជាសមូហភាពដែលមានសមធម៌។ ជាធម្មតាសហគមន៍នៅក្នុងប្រទេសកម្ពុជាមិនមានតំណាងដោយការបោះឆ្នោត។ ហើយរដ្ឋបាលភូមិដែលមានស្រាប់មិនមែនសុទ្ធតែអំណោយផលចំពោះការធ្វើសេចក្តីសម្រេចចិត្តរួមឡើយ។ប្រការនេះជាគោលគំនិតថ្មីមួយសម្រាប់សហគមន៍ច្រើនផងដែរ។
- កង្វះនៃស្ថាប័នតំណាងមូលដ្ឋានដែលមានការទទួលស្គាល់រឹងមាំដោយផ្លូវច្បាប់ដែលអាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លូវច្បាប់ក្នុងនាមអ្នកភូមិ។ ជាលិទ្ធិផលមានកិច្ចព្រមព្រៀងពីប្រភេទដែលត្រូវបានចុះហត្ថលេខា គឺមួយកិច្ចព្រមព្រៀងសហគមន៍ដែលចុះហត្ថលេខាដោយមេភូមិ និងឃុំ និងមួយ កិច្ចព្រមព្រៀងគ្រួសារដែលចុះហត្ថលេខាដោយគ្រួសារនីមួយៗ។
- ការគំរាមកំហែងធំៗចំពោះគម្រោង REDD+ ចេញពី សម្បទាន កសិឧស្សាហកម្មសកម្មភាពរុករករ៉ែការទន្ទ្រានយកដីពីសំណាក់ជនចំណាកស្រុក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការកាប់ឈើដោយគ្មាន់ការទប់ស្កាត់។ បញ្ហាទាំងអស់នេះសុទ្ធតែហួសពី សមត្ថភាពគ្រប់គ្រងរបស់សហគមន៍។ "សហគមន៍នៅតំបន់ សីមា បានត្អូញត្អែរថាព័ត៌មានអំពីការកាប់ព្រៃឈើខុសច្បាប់ ដែលពួកគេបានរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធពុំត្រូវបានដោះស្រាយឱ្យបានគួរជាទីគោរពពេញចិត្តឡើយ"។
- FPIC ចាំបាច់ត្រូវបន្តរហូតដល់ចុងបញ្ចប់នៃវដ្តគម្រោងជាមួយ នឹងតួនាទីរឹងមាំរបស់សហគមន៍មូលដ្ឋាននៅក្នុងការតាមដាន និងវាយតម្លៃផលប៉ះពាល់បរិស្ថាន។
- បច្ចុប្បន្នកម្ពុជាមានគម្រោង REDD+ សរុបចំនួន ៦ ដែលកំពុង អនុវត្ត ឬកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍។ ក្នុងនោះមានពីរ គម្រោងកំពុងឈានជិតដល់ការទទួលបានប្រាក់កម្រៃពីឥណទានកាបូនដែលជាលទ្ធផលនៃគម្រោង។ ដោយអនុលោមតាមបទប្បញ្ញត្តិនិងបទដ្ឋានអន្តរជាតិដែលមានស្រាប់ FPIC ត្រូវតែដាក់ បញ្ចូលទៅក្នុងគម្រោងទាំងនេះទាំងអស់។

## ២) ការកំណត់បែងចែកតំបន់នៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព (KPWS)

ការកំណត់បែងចែកតំបន់នៅក្នុងដែនជម្រកសត្វព្រៃ គូលែនព្រហ្មទេព (KPWS) គឺជាគម្រោងមួយផ្សេងទៀតដែលអនុវត្តដោយ WCS ដោយ សហការជាមួយក្រសួងបរិស្ថាននិងអាជ្ញាធរដែនដី។ ក្នុងអំឡុងឆ្នាំ២០១៧/១៨ សកម្មភាពកំណត់ការបែងចែកតំបន់នៅក្នុងតំបន់ការពារធម្មជាតិនេះត្រូវបានគាំទ្រមូលនិធិមួយផ្នែកដោយ MRLG។ ការកំណត់បែងចែកតំបន់ KPWS គឺផ្អែកលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (ឆ្នាំ២០០៨) មាត្រា ១១ ដែលកំណត់ពីភាពខុសគ្នានៃតំបន់ទាំងបួននៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ ៖ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ ការងារដែលអនុវត្តនៅក្នុង KPWS បានជួយផ្តល់ធាតុចូលសម្រាប់ «គោលការណ៍ណែនាំ ស្តីពីការកំណត់បែងចែកតំបន់សម្រាប់តំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា» ដែលត្រូវបានអនុម័តដោយក្រសួងបរិស្ថាននាឆ្នាំ ២០១៨។

សកម្មភាពកំណត់ការបែងចែកតំបន់នៅក្នុង KPWS បានចាប់ផ្តើមឡើងជាមួយនឹងការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ PA ដោយផ្តោតសំខាន់លើតំបន់និងកិច្ចព្រមព្រៀងជាមួយសហគមន៍ដែលចាប់អារម្មណ៍ចូលរួមនៅក្នុងការកំណត់បែងចែកតំបន់ហើយបន្ទាប់មកគឺការកំណត់អត្តសញ្ញាណនៃការប្រើប្រាស់និងសិទ្ធកាន់កាប់ដីកសិកម្មបច្ចុប្បន្ន និងការកំណត់តំបន់សហគមន៍។ ការប្រើប្រាស់ដីនិងការកាន់កាប់ដីធ្លី ត្រូវបានរកឃើញថាជាបញ្ហាសំខាន់ដែលសហគមន៍ចង់ដោះស្រាយ។ KPWS រួមមានភូមិចំនួន ២៨ និងអនុភូមិចំនួន ៨។ ចាប់ពីខែតុលា ឆ្នាំ ២០០៦ មកការកំណត់តំបន់បីផ្សេងទៀតក៏បានធ្វើឡើងតាមក្រោយជាបន្តបន្ទាប់។ ដើម្បីធានានូវភាពម្ចាស់ការពេញលេញទៅលើដំណើរការនេះនៅកម្រិតមូលដ្ឋាន ក្រុមការងារថ្នាក់ខេត្តត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលនិងអនុម័តសកម្មភាពបែងចែក តំបន់។ WCS បានផ្តល់ការបណ្តុះបណ្តាល FPIC ដល់សមាជិកក្រុមការងារថ្នាក់ខេត្តស្តីពីគោលការណ៍នៃ FPIC។ ទោះជាយ៉ាងនេះក្តី វិធីសាស្រ្តដែលគេជ្រើសរើសនៅក្នុងការបែងចែកតំបន់និងធ្វើផែនទីគឺការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ប៉ុន្តែមិនមែនជាការអនុវត្តពេញលេញស្តីពី FPIC ដែរ។ ដំណើរការនេះបានចាប់ផ្តើមជាមួយនឹងព្រឹត្តិការណ៍ពិគ្រោះយោបល់ នៅកម្រិត ឃុំនៅក្នុងគ្រប់ទាំង១១ឃុំដែលពាក់ព័ន្ធ។ បន្ទាប់មកទៀតគឺព្រឹត្តិការណ៍ពិគ្រោះយោបល់ភូមិនៅក្នុងភូមិសរុប ២៩ ភូមិ ដែលជាការពិគ្រោះយោបល់ផ្អែកទៅលើផែនទីព្រាងដែលបង្ហាញតំបន់ទាំង ៤ ដែលបានស្នើឡើងសម្រាប់ផ្នែកពាក់ព័ន្ធនៃតំបន់ការពារធម្មជាតិ។ កិច្ចប្រជុំ តាមភូមិមានប្រជាជនពី ២០ ទៅ ៥០ នាក់បានចូលរួមដោយក្នុងនោះក៏មានតំណាងស្ត្រីជាច្រើនផងដែរ។ កិច្ចពិភាក្សាផ្តោតទៅលើសិទ្ធដីធ្លីជាប្រពៃណីនិងទម្លាប់នៃការប្រើប្រាស់ធនធាន។ សម្រាប់គ្រប់ភូមិទាំងអស់ ផែនទីពីរខុសគ្នាត្រូវបានរៀបចំឡើងនៅក្នុងដំណាក់កាល ឬកិច្ចពិគ្រោះយោបល់ពីរផ្សេងគ្នា៖ ក) ផែនទីប្រើប្រាស់ដីកសិកម្ម (ចុះហត្ថលេខាដោយ

[2]Yeang Donal, et al. (2018) Editorial - REDD+ in Cambodia how local communities can benefit from forest conservation. Cambodian Journal of Natural History 2018 (2) 53 - 55.



ដោយអភិបាលស្រុក មេឃុំ និងមេភូមិ រហូតដល់ឆ្នាំ២០១៥) និង ខ) ផែនទីពិគ្រោះយោបល់ថ្នាក់ភូមិស្តីពីការបែងចែកតំបន់ (ចុះហត្ថលេខាដោយមេភូមិ និងមេឃុំ រហូតដល់ឆ្នាំ២០១៨)។ បន្ទាប់ពីកិច្ចប្រជុំពន្យល់បន្ថែម ផែនទីត្រូវបានដាក់បង្ហាញជាសាធារណៈសម្រាប់ រយៈពេល២សប្តាហ៍សម្រាប់ផែនទីនីមួយៗ។ បន្ទាប់មក អ្នកភូមិត្រូវបានជូនដំណឹងតាមរយៈគណៈកម្មាធិការតំបន់ការពារសហគមន៍ដែលមានស្រាប់ គ្រូបង្រៀន ព្រមទាំងមេឃុំ និងមេភូមិ។ ផ្ទាំងព័ត៌មានអំពីការបែងចែកតំបន់ទូទៅត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ជាព័ត៌មានបន្ថែម។ ផ្ទាំងព័ត៌មាននៃការបែងចែកតំបន់ក៏ផ្តល់នូវព័ត៌មានអំពីយន្តការសារទុក្ខផងដែរ។

ជាចុងក្រោយបង្អស់ ការយល់ព្រមរបស់អ្នកភូមិត្រូវបានស្តែងឡើងតាមរយៈការចុះហត្ថលេខារបស់មេភូមិនៅលើសេចក្តីព្រាងផែនទីកំណត់ និងបែងចែកតំបន់។ បន្ទាប់មកទៀត ផែនទីក៏ត្រូវបានចុះហត្ថលេខាដោយមេឃុំ អភិបាលស្រុក និងនៅចុងក្រោយគេបង្អស់គឺហត្ថលេខារបស់ លោកអភិបាលខេត្តរង បន្ទាប់ពីមានការយល់ព្រមតាមរយៈសមាជិកនៃក្រុមការងារថ្នាក់ខេត្ត។

ក្នុងអំឡុងពេលពីដើមរហូតដល់ចប់នៃដំណើរការនេះ ការកែប្រែខ្លះៗទៅលើព្រំប្រទល់នៃតំបន់ទាំងបួនត្រូវបានដាក់បង្ហាញជូនទៅអ្នកភូមិឡើយ ហើយមានការកែសម្រួលបន្តិចបន្តួចប៉ុណ្ណោះដែលត្រូវបានពិចារណានិងអនុម័តនៅក្នុងអំឡុងពេលពិនិត្យសម្រេចចុងក្រោយទៅលើតំបន់ ធ្វើឡើងដោយក្រុមការងារថ្នាក់ខេត្ត (សិក្ខាសាលាថ្នាក់ខេត្ត) ជាពិសេស ពាក់ព័ន្ធនឹងតំបន់បន្ថែមដែលបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ចទៅឱ្យមន្ត្រីយោធានិងយោធិនចូលនិវត្តន៍។ ឥឡូវនេះ ផែនការបែងចែកតំបន់ស្ថិតនៅក្នុងជំហានចុងក្រោយបង្អស់នៃការធ្វើបញ្ចប់ជាស្ថាពរ។

## មេរៀនពីការកំណត់បែងចែកតំបន់នៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ( KPWS )

- គោលការណ៍ FPIC មិនបានអនុវត្តពេញលេញនោះទេនៅក្នុងករណីនៃការកំណត់បែងចែកតំបន់ KPWS។ ព្រឹត្តការណ៍ពិគ្រោះយោបល់ភូមិត្រូវបានធ្វើឡើងដោយផ្តោតសំខាន់ទៅលើការកំណត់ព្រំប្រទល់តំបន់សហគមន៍ប៉ុន្តែការបែងចែកតំបន់សំខាន់ៗនៃតំបន់បីផ្សេងទៀត ត្រូវបានកំណត់ជាមុន ហើយនៅទីបំផុត អ្នកភូមិត្រូវបានស្នើឱ្យផ្តល់ការយល់ព្រមទៅលើតំបន់ទាំងបួនតែម្តង។ មានអត្ថាធិប្បាយ ឬយោបល់តិចតួចប៉ុណ្ណោះដែលបានទទួលពីអ្នកភូមិដែលចូលរួម។ការដាក់បញ្ចូលទស្សនៈ របស់អ្នកភូមិចំពោះការបែងចែកតំបន់ការពារគួរត្រូវបានអនុវត្តជំហានបន្ថែមទៀតនាពេលអនាគត។
- តំបន់ដែលបានលើកជាសំណើគឺផ្អែកលើការគូសផែនទីដែលធ្វើឡើងដោយមានការណែនាំពីបុគ្គលិកបច្ចេកទេសហើយបន្ទាប់ពីថ្នាក់ឃុំបានពិនិត្យមើលតំបន់ដែលបានស្នើឡើងកិច្ចប្រជុំថ្នាក់ភូមិត្រូវបានធ្វើឡើងនៅតាមភូមិសំខាន់ៗ។
- ព្រំប្រទល់សម្រេចចុងក្រោយ នៃតំបន់នានាពុំឆ្លុះបញ្ចាំងដំណើរការធ្វើសម្រេចចិត្តនៅភូមិពិតប្រាកដនោះទេ។ វានៅតែជាបញ្ហាចោទដដែលថាតើហត្ថលេខាសម្រេចរបស់មេភូមិតំណាងឱ្យការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយក្នុងកម្រិតណា ទៅលើការកំណត់បែងចែកតំបន់បានស្នើឡើង។
- ភាពប្រឈមសំខាន់ៗគឺជនចំណូលស្រុកថ្មីដែលមិនត្រូវបានរាប់បញ្ចូលទៅក្នុងភូមិដែលមានស្រាប់ ប៉ុន្តែពួកគេបង្កើតតំបន់លំនៅដ្ឋានថ្មីៗដោយខ្លួនឯង។ ដូចច្នេះហើយជនចំណូល ស្រុកទាំងនោះមិនបានដឹងអំពីការកំណត់បែងចែកតំបន់PA ឡើយ។ កំណើនប្រជាជន ៣០% ត្រូវបានសង្កេតកើតមានចាប់តាំងពីឆ្នាំ ២០១២ មកម្ល៉េះដោយសារជនចំណូលស្រុកថ្មីសម្រុកចូលមកកាន់តំបន់នេះ។

## ៣) «អគារ ស» ៖ ការអភិវឌ្ឍអចលនទ្រព្យទីក្រុងឡើងវិញនៅរាជធានីភ្នំពេញ

អគារ ស ដែលគេស្គាល់ជាទូទៅថា ប្លុកប៊ូឌីញ គឺជាអគារផ្ទះល្វែងដែលមានទំហំ ២២.៩៩២ ម៉ែត្រការ៉េ ដែលមានផ្ទះល្វែងចំនួន ៤៦២ល្វែង មានប្រជាជនរស់នៅចំនួន ២.៨៨៣នាក់ ស្មើនឹង ៥៣២គ្រួសារ។ សហគមន៍នេះរួមមានពលរដ្ឋខ្មែរ ខ្មែរកម្ពុជាក្រោម ជនជាតិចាម និងជនជាតិវៀតណាម។ ពួកគេភាគច្រើនបម្រើការងារជាមន្ត្រីរាជការ។ អគារ ស មានទីតាំងស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

អគារ ស» នេះបានចាប់ផ្ដើមសាងសង់ឡើងនៅឆ្នាំ១៩៦១ ជាជម្រើសលំនៅដ្ឋានធូរថ្លៃសម្រាប់ ក្រុមគ្រួសារដែលមានជីវភាពទាបនិងមធ្យម។ ហើយកាលជំនាន់ខ្មែរក្រហម អគារនេះត្រូវបានទុកចោលបន្ទាប់ពីប្រជាជនទីក្រុងត្រូវបានជម្លៀសចេញពីរាជធានីភ្នំពេញនៅឆ្នាំ១៩៧៥។ អគារ ស ចាប់ផ្ដើមមានប្រជាជនចូលរស់នៅវិញចាប់តាំងពីឆ្នាំ ១៩៧៩ និងក្នុងអំឡុងទសវត្សរ៍ ១៩៨០។ ក្នុងអំឡុងទសវត្សរ៍ ១៩៩០ ការបម្លាស់ទីមករស់នៅទីក្រុងបាននាំឱ្យមានកំណើនយ៉ាងគំហុកនៃតម្រូវការសម្រាប់លំនៅដ្ឋានស្នាក់នៅនិងភាពងាយស្រួលក្នុងការទទួលសេវា សាធារណៈ។ អគារ ស គឺជាកន្លែងស្នាក់នៅដ៏ពេញនិយមដោយសារតែវាមានទីតាំងស្ថិតនៅជិតសាលារៀន មន្ទីរពេទ្យ និងផ្សារនានា។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០០០ ទំហំគ្រួសារមធ្យមបានរីកកាន់តែធំ ហើយផ្ទះល្វែងជាច្រើនត្រូវបានកែច្នៃនិងពង្រីកឡើងវិញ។

ការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ (SLR) មិនបានអនុវត្តចំពោះអគារ ស ទេ។ ដូច្នេះការកំណត់អំពីការកាន់កាប់ស្របច្បាប់ទៅលើដីនិងអគារនេះនៅតែមិនមានភាពច្បាស់លាស់។ជាងនេះទៅទៀតពុំមានគ្រួសារណាមួយទទួលបានប័ណ្ណកម្មសិទ្ធដីធ្លីស្របច្បាប់ដែលផ្ដល់ឱ្យតាមរយៈការចេញប័ណ្ណកម្មសិទ្ធដីធ្លីដាច់ដោយឡែកឡើយ។ ប៉ុន្តែអ្នករស់នៅតំបន់នេះមានអត្តសញ្ញាណបណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងសំបុត្រកំណើត ដើម្បីបញ្ជាក់អាសយដ្ឋាននិងរយៈពេលកាន់កាប់និងស្នាក់នៅក្នុងអគារនេះរបស់ពួកគេ។ ពួកគេក៏មាននូវបង្កាន់ដៃទិញលក់ដែលចេញដោយសង្កាត់នៅពេលដែលផ្ទះល្វែងនានាត្រូវបានផ្ទេរពីម្ចាស់កម្មសិទ្ធម្នាក់ទៅម្នាក់ទៀត។

នៅចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៦ រដ្ឋបាលមូលដ្ឋាននិងស្ថាប័នរដ្ឋាភិបាលថ្នាក់កណ្ដាល កាន់តែមានការព្រួយបារម្ភខ្លាំងឡើងៗ។ នៅខែកក្កដា ឆ្នាំ ២០១៥ ដោយសារបារម្ភអំពីស្ថានភាពសំណង់តួអគារ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខណ្ឌចំការមនបានថ្លែងថា អគារនេះចាស់ទ្រុឌទ្រោមខ្លាំង មានប្រជាជននៅច្រើនហួសប្រមាណ និងថាមានការជួសជុលកែលម្អដោយខុសច្បាប់ទៅលើអគារនេះ និងមិនមានការថែទាំត្រឹមត្រូវ។ អាជ្ញាធរបានរៀបចំវេទិកាសាធារណៈដើម្បីដោះស្រាយបញ្ហានេះ ដែលនៅក្នុងវេទិកានោះអ្នករស់នៅទីនោះត្រូវបានផ្ដល់ការធានាអះអាងថានឹងមិនមានការបណ្ដេញចេញដោយបង្ខំឡើយ។ ទោះជាយ៉ាងនេះក្ដី នៅឆ្នាំ២០១៦ អគារ ស ត្រូវបានកំណត់ថាមានសភាពទ្រុឌទ្រោមនិងមិនស័ក្តិសមសម្រាប់ការរស់នៅឡើយ។ រដ្ឋាភិបាលបានគ្រោងវាយកម្ទេចអគារនេះចោលនៅឆ្នាំ២០១៧។

នៅចុងឆ្នាំ២០១៦ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) បានប្រកាសថា ក្រុមហ៊ុនជប៉ុនមួយ ឈ្មោះ Arakawa ត្រូវបានផ្ដល់កិច្ចសន្យាសាងសង់អគារ ២១ជាន់ នៅលើទីតាំងអគារ ស នេះ ក្នុងតម្លៃទឹកប្រាក់សរុប ៧០-៨០លានដុល្លារអាមេរិក។ ក្នុងចំណោម ២១ ជាន់ដែលបានស្នើឡើងនេះមាន៨ជាន់នឹងត្រូវបម្រុងទុកសម្រាប់គ្រួសារចំនួន ៥៣២ គ្រួសារដែលបានរស់នៅលើអគារ ស នេះពីមុនមក។ ការស្នាក់នៅបណ្ដោះអាសន្នសម្រាប់ប្រជាជនក្នុងពេលនៃការសាងសង់ត្រូវបានគិតគូរទុកជាមុន។

កិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើកច្រើនសាបានរៀបចំឡើងរវាងអ្នករស់នៅលើអគារ ស ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រុមហ៊ុន Arakawa។ កិច្ចពិគ្រោះយោបល់ដំបូងៗបានរៀបចំឡើងនៅនឹងកន្លែង។ ពុំមានអង្គការក្រៅរដ្ឋាភិបាលណាចូលរួមពាក់ព័ន្ធដោយផ្ទាល់នៅក្នុងកិច្ចពិគ្រោះយោបល់ឬការចរចានេះឡើយ។ ទោះជាយ៉ាងណានេះក្ដី សហគមន៍ក៏មានទំនាក់ទំនងជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលខ្លះដែលបានផ្ដល់ការគាំទ្រសម្រាប់ការជួសជុលនិងការថែទាំអគារនេះ ព្រមទាំងការការពារសិទ្ធរបស់ពួកគេផងដែរ។ក្រុមការងារសិទ្ធមនុស្ស(HRTF)បានផ្ដល់ការគាំទ្រដល់សហគមន៍ដើម្បីពិភាក្សាអំពីសិទ្ធរបស់ពួកគេរៀបចំបង្កើតយុទ្ធសាស្ត្រនានា និងធ្វើការវាយតម្លៃទៅលើលទ្ធផលដែលអាចកើតមានឡើង។ ទន្ទឹមនឹងនោះ HRTF ក៏បានយកចិត្តទុកដាក់ស្ដាប់ក្ដី កង្វល់និងមតិត្រឡប់របស់អ្នករស់នៅសហគមន៍អគារ ស នេះផងដែរ។

*White building in Phnom Penh. Photo credit: Nicole Shin*



អ្នកភូមិត្រូវបានផ្ដល់ជម្រើសមួយក្នុងចំណោមជម្រើសពីរគឺៈ កញ្ចប់សំណងជាលុយ ឬផ្ទះល្វែងនៅលើអគារសង់ថ្មី។ អ្នករស់នៅទីនេះ ៩០%បានជ្រើសរើសយកសំណងជាលុយ។ សេចក្ដីសម្រេចចិត្តនេះ ពិតប្រាកដណាស់គឺទទួលរងឥទ្ធិពលពីបទពិសោធន៍អាក្រក់នាពេលកន្លងមកជាពិសេសបទពិសោធន៍របស់ប្រជាជនដែលរស់នៅតំបន់បុរីកីឡា។ការចរចាចុងក្រោយអំពីសេចក្ដីលម្អិតនៃការរៀបចំសំណងត្រូវបានធ្វើឡើងនៅទីស្ដីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមការដឹកនាំប្រជុំដោយផ្ទាល់ពីសំណាក់ឯកឧត្ដមទេសរដ្ឋមន្ត្រី ជា សុផារ៉ា។ គេដឹងព័ត៌មានតិចតួចប៉ុណ្ណោះអំពីលក្ខណៈនៃការតំណាងឱ្យប្រជាជននៅក្នុងកិច្ចប្រជុំទាំងនេះអំពីសំណើរនិងការទាមទាររបស់ពួកគេ ឬអំពីបរិយាកាសនៃកិច្ចប្រជុំទាំងនេះ។ ពុំមានប្រជាជនណាមួយមានសិទ្ធជួបប្រជុំដោយផ្ទាល់ជាមួយក្រុមហ៊ុនវិនិយោគឡើយ។

ប៉ុន្តែទោះយ៉ាង ណា នៅចុងបញ្ចប់ទៅ ពោលគឺនៅពាក់កណ្ដាលឆ្នាំ២០១៧ ជាង៩៥% នៃគ្រួសារពាក់ព័ន្ធបានព្រមព្រៀងទទួលយកកញ្ចប់សំណងនិងចាកចេញពីអគារនេះ។ ពួកគេបានយល់ព្រមលក់ផ្ទះល្វែងចាស់ទ្រុឌទ្រោមរបស់ពួកគេក្នុងតម្លៃ ១.៤០០ដុល្លារ ក្នុងមួយម៉ែត្រការ៉េ បើទោះបីជាមានអ្នកខ្លះដាស់តឿនថាតម្លៃនេះអាចឡើងខ្ពស់ទៅដល់ ២.០០០ដុល្លារ ក្នុងមួយម៉ែត្រការ៉េ ក្ដីបើយោងតាមអត្រាតម្លៃទីផ្សារ។កិច្ចសម្ភាសន៍ជាមួយអតីតអ្នករស់នៅលើអគារ ស បានបង្ហាញថា ភាគច្រើននៃអតីតប្រជាជនរស់នៅលើអគារ ស បានថ្លែងអំណរគុណចំពោះ កិច្ចប្រឹងប្រែងពិគ្រោះយោបល់ក្នុងការស្វែងរកដំណោះស្រាយត្រឹមត្រូវសម្រាប់អ្នករស់នៅលើអគារ ស គ្រប់រូបជាមួយនឹងការផ្ដល់សំណងដែលអាចទទួលយកបានដោយស្ម័គ្រចិត្តនិងដោយគ្មានការបង្ខិតបង្ខំ។ ដំណើរការនៃការផ្ដល់សំណងនៅក្នុងការអភិវឌ្ឍឡើងវិញនូវអគារ ស នេះមានភាពរលូនជាងគម្រោងផ្សេងៗទៀត។

ថ្មីៗនេះ MLMUPC បានចេញផ្សាយសៀវភៅមួយដែលលម្អិតអំពីដំណើរការនៃការអភិវឌ្ឍនៅលើទីតាំងអគារ ស នៅរាជធានីភ្នំពេញនៅមុនការវាយកម្ទេចចោលសំណង់អគារជានិមិត្តរូបនេះនៅឆ្នាំ២០១៧ ដោយផ្ដល់ជាគំរូមួយសម្រាប់គម្រោងអភិវឌ្ឍន៍ឡើងវិញ បើយោងតាមប្រសាសន៍ របស់រដ្ឋមន្ត្រី MLMUPC។បើទោះបីជាករណីនៃអគារ ស នេះមិនឆ្លុះបញ្ចាំងនូវអភិក្រម FPIC មួយដែលពេញលេញក្ដីវាពិតជាផ្ដល់នូវមេរៀនពាក់ព័ន្ធមួយចំនួនស្ដីពីការពិគ្រោះយោបល់ជាមួយប្រជាជនដែលរងប៉ះពាល់ដោយសារគម្រោង។

## មេរៀនពីករណី «អគារ ស»

- នៅក្នុងវិសាលភាពនៃការអភិវឌ្ឍទីក្រុងឡើងវិញនៅប្រទេសកម្ពុជាដែលបានបង្ហាញឱ្យឃើញនូវគំរូជាច្រើន នៃការបណ្ដេញចេញ ដោយបង្ខំកាលពីពេលកន្លងមកនិងដែលជានិច្ចកាលបន្សល់ទុកនូវជម្លោះរ៉ាំរ៉ៃ។ ករណីអគារ ស ជាករណីលេចធ្លោមួយដែលគេបានរកឃើញដំណោះស្រាយប្រកបដោយសន្តិវិធី និងជាទីពេញចិត្តសម្រាប់អតីតអ្នករស់លើអគារ ស។ សំណងដែលបានផ្ដល់មិនបានឆ្លើយតាមទៅនឹងកម្រិតទីផ្សារទេ ប៉ុន្តែជាទូទៅត្រូវចាត់ទុកថាអាចទទួលយកបាន។
- ការចរចាដោយផ្ទាល់រវាងពលរដ្ឋ និងរដ្ឋមន្ត្រី MLMUP និងបុគ្គលិករបស់លោកដោយគ្មានវត្តមាននៃអ្នកសង្កេតការណ៍ណាម្នាក់មិនមែនជាការធានានូវសមធម៌និងសមភាពនោះទេ។ ម៉្យាងវិញទៀត ការចរចាទាំងនេះបានផ្ដល់ជាវេទិការមួយសម្រាប់រចនាសម្ព័ន្ធធ្វើការប្រកបដោយប្រសិទ្ធភាពនិងការធ្វើសេចក្ដីសម្រេចចិត្តបានឆាប់រហ័ស។ការដែលពលរដ្ឋត្រូវបានផ្ដល់ដំណឹងអាចជ្រើសរើសជម្រើសនានា និងត្រូវបានយកចិត្តទុកដាក់ស្ដាប់កង្វល់របស់ពួកគេបានផ្ដល់ជាធាតុសំខាន់ៗ សម្រាប់ដំណើរពិគ្រោះយោបល់មួយដែលមានភាពរឹងមាំ។
- ក្រុមហ៊ុនជប៉ុន Arakawa បានបង្ហាញនូវការគោរពកម្រិតខ្ពស់ចំពោះអតីតអ្នករស់នៅលើអគារ ស និងមានបទដ្ឋានទំនួលខុសត្រូវសង្គម(CSR)រឹងមាំនៅក្នុងដំណើរការនៃការពិគ្រោះយោបល់។ នៅប្រទេសជប៉ុន ក្រុមហ៊ុន Arakawa ស្ថិតក្រោមការតាមដានយ៉ាងជិតដិតពីសំណាក់អង្គការសិទ្ធមនុស្សរបស់ជប៉ុន។
- ការងារកាលពីពេលថ្មីៗកន្លងមករបស់ MLMUPC នៅក្នុងការចងក្រងឯកសារ អំពីករណីនេះផ្ដល់នូវក្ដីសង្ឃឹមថាករណីនេះអាចក្លាយជាករណីគំរូ នៃការបង្កើតការចូលរួមនិងការពិគ្រោះយោបល់ជាមួយពលរដ្ឋនៅក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងឡើងវិញ និងជាជំហានដំបូងឆ្ពោះទៅរកការពិចារណាអនុវត្ត FPIC ពេញលេញ។

## ៤) ការវិនិយោគលើវិស័យកសិកម្មនិងព្រៃឈើ ដោយក្រុមហ៊ុន Grandis Timber

ក្រុមហ៊ុន Grandis Timber គ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច (ELC) នៅខេត្តកំពង់ស្ពឺ សម្រាប់ការដាំដើមម៉ៃសាក់។ ទំហំសរុបនៃ ELC នេះគឺ ៧.៨៥៩ហិកតា ប៉ុន្តែក្នុងនោះមាន ២.២៥៩ហិកតា ជាតំបន់ដែលមិនអាចប្រើប្រាស់សម្រាប់ការដាំចម្ការម៉ៃសាក់បានទេ។ វាជាតំបន់ដែលទទួល ខុសត្រូវការពារដោយរដ្ឋបាលព្រៃឈើ (FA) ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការអភិរក្សអន្តរជាតិ (CI) និងអង្គការសម្ព័ន្ធសត្វព្រៃ (Wildlife Alliance) ។

ភាគច្រើនលើសលប់នៃ ELCs នៅកម្ពុជាមិនដែលធ្វើ EIA ទេ។ នៅក្នុងករណីក្រុមហ៊ុន Grandis Timber ក្រុមហ៊ុនបានអនុវត្តដំណើរការ EIA ដល់ទៅពីរលើកឯណោះ។ EIA ទីមួយកំណត់អំពីភាពចាំបាច់ក្នុងការផ្តល់ការការពារជាពិសេសដល់ផ្នែកខ្លះនៃតំបន់ ហើយផ្នែកទាំងនេះបានក្លាយ ជាតំបន់អភិរក្សបច្ចុប្បន្ន។ EIA ទីពីរនិងដែលមានលក្ខណៈពេញលេញដែលបានធ្វើឡើងក្នុងអំឡុងឆ្នាំ២០០៩/២០១០ បានអនុវត្តទៅតាមគ្រប់ជំហានដូចដែលបានកំណត់ដោយច្បាប់កម្ពុជា។ ប៉ុន្តែរយៈពេល៣០ថ្ងៃសម្រាប់ការបិទបង្ហាញជាសាធារណៈដើម្បីផ្សព្វផ្សាយជាព័ត៌មាន មិនត្រូវបានគេចាត់ទុកថាជាពេលវេលាគ្រប់គ្រាន់ឡើយ។ ការចូលរួមជាសាធារណៈនៅក្នុងដំណើរការ EIA មានតិចតួចប៉ុណ្ណោះ។

នៅពេលចាប់ផ្តើមនៃគម្រោងក្នុងឆ្នាំ២០០៩ ពុំមានគ្រួសារអ្នកស្រុករស់នៅក្នុងតំបន់ព្រៃរេចរឹល ដែលទុកសម្រាប់ជា ELC នោះទេ។ ប្រជាជនក្នុងមូលដ្ឋានទើបតែបានចាប់ផ្តើមរើមកបោះទីតាំងរស់នៅនៅពេលដែលគេចាប់ផ្តើមការសាងសង់ផ្លូវតែប៉ុណ្ណោះ។ បច្ចុប្បន្នមានអ្នកស្រុកដល់ទៅ ១៨២ គ្រួសារ (ជាជនជាតិខ្មែរទាំងអស់) រស់នៅក្នុងភូមិចំនួន ៣ (មួយភូមិនៅក្នុងស្រុកឱរ៉ាល់ និងពីរភូមិទៀតនៅស្រុកភ្នំស្រួច) ដែលពួកគេទាំងនេះរស់នៅជាប់ក្បែរៗនឹងតំបន់ ELC។ គ្រួសារជាច្រើនបានទាមទារដីជាប្រពៃណីនៅក្នុងតំបន់ ELC នៅពេលដែលការអនុវត្តគម្រោងបានចាប់ផ្តើមឡើង។

ក្រុមហ៊ុន Grandis Timber បង្ហាញខ្លួនជាវិនិយោគិនលេចធ្លោមួយដែលមានបទដ្ឋានទំនួលខុសត្រូវសង្គម (CSR) ខ្ពស់មានគោលបំណងតាំងពីដើមទីដើម្បីសម្រេចបាននូវការទទួលវិញ្ញាបនបត្របញ្ជាក់ពេញលេញមួយពី Forest Stewardship Council (FSC) សម្រាប់ដំណាំចម្ការរបស់ខ្លួន និងបានព្យាយាមធ្វើឱ្យមានតម្លាភាពតាមលទ្ធភាពដែលអាចធ្វើបានពាក់ព័ន្ធនឹងវិនិយោគរបស់ខ្លួន។ ចាប់តាំងពីដំណាក់កាលដំបូងៗនៃការអនុវត្តគម្រោងក្រុមហ៊ុន Grandis Timber បានសុំការណែនាំនិងការគាំទ្រពីអង្គការដែលមានជំនាញផ្សេងៗទៅលើបញ្ហានានាដូចជាការកាន់កាប់ដីធ្លី (អង្គការ GIZ) និងបញ្ហាការពារបរិស្ថាន (អង្គការ CI និង WA) ព្រមទាំងរក្សាការប្រាស្រ័យទាក់ទងគ្នារឹងមាំជាមួយក្រសួង រុក្ខាប្រមាញ់ និងនេសាទ (MAFF) នៅលើគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រង ELC។

ដូចដែលកើតមាននៅក្នុង ELCs ភាគច្រើនលើសលប់ដែរ ករណីក្រុមហ៊ុន Grandis Timber ក៏មានបញ្ហាព្រំប្រទល់មួយចំនួនរវាងដីឯកជន តំបន់គ្រង់គ្រងរួម និងដីរដ្ឋដែលកាត់ទុកជា ELC។ អនុសាសន៍បឋមដ៏សំខាន់មួយដែលអ្នកជំនាញបានផ្តល់គឺធ្វើយ៉ាងណាកាត់ខ្សៀលចេញនូវរាល់តំបន់ទាំងឡាយណាដែលស្ថិតក្រោមការកាន់កាប់របស់ប្រជាជនមូលដ្ឋាន។ នៅឆ្នាំ២០១២ ដីធ្លីរបស់គ្រួសារទាំងអស់ដែលរស់នៅក្នុងតំបន់ក្បែរខាងត្រូវបានវាស់វែងនិងទទួលបានសារាចរណែនាំលេខ ០១ ស្តីពីប័ណ្ណកម្មសិទ្ធដីឯកជន។ ការងារវាស់វែងនេះត្រូវបានគាំទ្រយ៉ាងសកម្មនិងត្រូវបានជំរុញលើកកម្ពស់ដោយក្រុមហ៊ុន។

ចាប់តាំងពីឆ្នាំ២០១៧ មក ELC នេះត្រូវបានវាស់វែងឡើងវិញ ហើយប័ណ្ណកម្មសិទ្ធដីរដ្ឋត្រូវបានផ្តល់ឱ្យដល់តំបន់នេះក្នុងនាម MAFF។ ប័ណ្ណកម្មសិទ្ធនេះត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុន Grandis Timber ស្របទៅតាមកិច្ចព្រមព្រៀង ELC។ ទោះបីមានការបញ្ជាក់ច្បាស់លាស់អំពីសិទ្ធកាន់កាប់ដីធ្លីតាមរយៈការធ្វើប័ណ្ណកម្មសិទ្ធ ករណីជាច្រើននៃការឈ្លានពានចូលតំបន់របស់ក្រុមហ៊ុនត្រូវបានសង្កេតឃើញមានកាលពីប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រការនេះ បានបង្ខំឱ្យក្រុមហ៊ុនត្រូវចុះកិច្ចព្រមព្រៀងដាច់ដោយឡែកទៀតនៅក្នុងគ្រប់ករណីអស់ទាំងនេះទោះបីក្នុងរូបភាពជាការបោះបង្គោលព្រំអចិន្ត្រៃយ៍ (ជាង ២០០ កិច្ចព្រមព្រៀង) ឬកិច្ចព្រមព្រៀងផ្សេងទៀតដែលទាក់ទិននឹង ឧទា. ចម្ការថ្មីៗ ឡដុតធ្យូងនៅក្នុងព្រៃ និងសកម្មភាពកាប់ឈើ។ ជាសរុប កិច្ចព្រមព្រៀងដាច់ដោយឡែកចំនួនជាង ៨០០ ត្រូវបានចុះហត្ថលេខាកន្លងមក ហើយក្រុមហ៊ុនរក្សាទុកបុគ្គលិក ៣នាក់ ដើម្បីឱ្យគ្រប់គ្រងការប្រាស្រ័យទាក់ទងគ្នាជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។



ដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទងគ្នានិងសហប្រតិបត្តិការជាមួយរដ្ឋបាលមូលដ្ឋាននិងអ្នកភូមិ «គណៈកម្មាធិការទទួលបន្ទុកទំនាក់ទំនងពាក់ព័ន្ធនឹង ELC របស់ Grandis Timber» (ហៅម្យ៉ាងទៀតថាជា ក្រុមការងារអន្តរសហគមន៍) ត្រូវបានបង្កើតឡើងដោយប្រកាសរួមរបស់ក្រុមប្រឹក្សាឃុំចំនួនពីរដែលពាក់ព័ន្ធ។ ក្រុមការងារនេះរួមមានសមាសភាពជំទប់ឃុំពីររូប ជាសមាជិកអចិន្ត្រៃ តំណាងអ្នកភូមិ និងក្រុមហ៊ុន (សរុប ១១ នាក់)។ ក្រុមការងារនេះជួបប្រជុំគ្នាជារៀងរាល់ត្រីមាស និងរៀបចំកិច្ចប្រជុំបន្ថែមក្នុងករណីមានបញ្ហាចាំបាច់ដើម្បីពិភាក្សាគ្នា។ ក្នុងទស្សនៈរបស់ក្រុមហ៊ុន ការបង្កើតក្រុមការងារនេះមានសារៈសំខាន់ណាស់ក្នុងការទទួលបានមតិត្រឡប់ពីសហគមន៍ ប្រាស្រ័យទាក់ទងគ្នា និងពិភាក្សាបញ្ហានានាដែលពាក់ព័ន្ធនឹងក្រុមហ៊ុន ព្រមទាំងតាមដានការអនុវត្តគម្រោងស្របទៅតាមផែនការនិងទិន្នន័យ EIA។ ប៉ុន្តែគេត្រូវ បានទទួលស្គាល់ថា ការខ្វែងគំនិតគ្នានៅតែមាននៅឡើយ ហើយសមាជិកនៅក្នុងក្រុមការងារ ក៏ចាប់ផ្តើមកសាងទំនាក់ទំនងការងារផងដែរ។

ក្រុមហ៊ុនទទួលបានសំណើជាច្រើនពីប្រជាជនបើទោះបីជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមសំខាន់ៗបានទទួលការគាំទ្រមូលនិធិ និងបានអនុវត្តជាច្រើនរួចមកហើយក្តី (ឧទា. គ្លីនិកមួយដែលមានសេវាគ្រូពេទ្យ សាលាបឋមសិក្សា និងមជ្ឈមណ្ឌលមើលថែក្មេង ព្រមទាំង មជ្ឈមណ្ឌលបណ្តុះបណ្តាល (ដែលភាគច្រើនប្រើប្រាស់ជាកន្លែងសម្រាប់ប្រជុំ)។ យោងតាមតំណាងរបស់ក្រុមហ៊ុន ការត្អូញត្អែរនិងអាកប្ប កិរិយាអវិជ្ជមានចំពោះគម្រោងនៅតែកើតមាននៅក្នុងចំណោមប្រជាជននៅក្នុងមូលដ្ឋាន។ គ្រួសារថ្មីៗបានបន្តផ្លាស់មករស់នៅក្នុងតំបន់នេះ។

### មេរៀនពីករណីក្រុមហ៊ុន Grandis Timber

- ករណីក្រុមហ៊ុន Grandis Timber មិនមែនជាគំរូនៃ FPIC ទេ ប៉ុន្តែផ្តល់នូវឧទាហរណ៍សំខាន់ៗសម្រាប់ការប្រាស្រ័យទាក់ទងគ្នានិងការពិគ្រោះយោបល់ទូលំទូលាយនិងជានិរន្តរ៍ជាមួយប្រជាជនរងផលប៉ះពាល់។ ហើយសម្រាប់ការវាយតម្លៃឡើងវិញជាប្រចាំទៅលើកិច្ចព្រមព្រៀងណាមួយដែលបានកើតឡើងជាមួយសហគមន៍។
- ការចូលរួមនិងការពិគ្រោះយោបល់កាន់តែរឹងមាំរបស់ប្រជាជននៅក្នុងអំឡុងពេលអនុវត្ត EIA នឹងមានអត្ថប្រយោជន៍បន្ថែមទៀតហើយអាចនឹងជួយធ្វើឱ្យប្រសើរឡើងថែមទៀតនូវការយោគយល់គ្នានិងការគាំទ្រចំពោះគម្រោង។
- ការបញ្ជាក់ច្បាស់លាស់អំពីសិទ្ធកាន់កាប់ដីធ្លី នៅដំណាក់ដំបូងគឺជាកត្តាសំខាន់ណាស់ សម្រាប់ជោគជ័យរបស់គម្រោងជោគជ័យរបស់គម្រោង។
- ក្រុមការងារឬគណៈកម្មាធិការ ដែលមានសមាជិកមកពីអជ្ញាធរដែនដី តំណាងអ្នកភូមិពាក់ព័ន្ធ និងក្រុមហ៊ុន ដើម្បីពិគ្រោះយោបល់លើរាល់បញ្ហាទាំងអស់ ដែលទាក់ទិននឹងការអនុវត្តគម្រោងចរចាកិច្ចព្រមព្រៀង និងស្វែងរកដំណោះស្រាយរួម គឺជាកត្តាដ៏សំខាន់ចាំបាច់ហើយគួរចាប់ផ្តើមពីដំណាក់កាលពិគ្រោះយោបល់ធ្វើ EIA ទៅ។
- ទោះបីមានកិច្ចប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីបង្កើតវេទិកាជាទៀតទាត់មួយសម្រាប់ការពិគ្រោះយោបល់ក្តី ក៏នៅតែមានការឈ្លានពានចូលជាហូរហែពីសំណាក់ប្រជាជននៅមូលដ្ឋាននិងជនចំណូលថ្មីមកក្នុងតំបន់ ELC ។ គេត្រូវកំណត់រកវិធីបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហាទាំងនេះ ដូចជា ក្នុងន័យជាការបែងចែកដីធ្លីទៅដល់ប្រជាជ ខ្វះដីឬទប់ស្កាត់ការទន្ទ្រានចូលពីសំណាក់ក្រុមឱកាសនិយម។

## សេចក្តីសន្និដ្ឋាន

នៅក្នុងប្រទេសកម្ពុជាមានឧទាហរណ៍ល្អៗជាច្រើនអំពីការពិគ្រោះយោបល់គ្នាដ៏រឹងមាំ រវាងតំណាងរដ្ឋាភិបាល ក្រុមហ៊ុន និងសហគមន៍ ក្រុមហ៊ុន និងសហគមន៍ មូលដ្ឋាន។ នៅក្នុងករណីមួយដំណើរការ FPIC ពេញលេញត្រូវបានអនុវត្តប្រកបដោយជោគជ័យ។ បច្ចុប្បន្ន វាជាការសមស្របនិងចាំបាច់ដែលគេត្រូវជំរុញនិងលើកកម្ពស់ការអនុវត្ត FPIC តាមរយៈការកសាងបរិយាកាសគោលនយោបាយល្អនៅក្នុងវិស័យនានានិងតាមរយៈការបន្តកែលម្អការអនុវត្តឥតឈប់ឈរ៕



សម្រង់ឯកសារយោងទាំងស្រុង៖ Rock, F. (២០១៩)។ ការអនុវត្តបទដ្ឋាននៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) នៅក្នុងប្រទេសកម្ពុជា, ឯកសារពិភាក្សា ទី៥។ វៀងចន្ទន៍៖ អភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ។

ពិនិត្យដោយ៖ Samia Slimane (UNOHCHR), Antoine Deligne និង Sothath Ngo (MRLG)

កិច្ចការនេះផ្តល់អាជ្ញាប័ណ្ណនៅក្រោមគោលការណ៍ Creative Commons Attribution-NonCommercial-ShareAlike 4.0 International (CC BY-NC-SA 4.0)

គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ (MRLG) មានគោលបំណងលើកកម្ពស់សន្តិសុខនៃសិទ្ធកាន់កាប់ដីធ្លីរបស់កសិករខាតតូចនៅក្នុងតំបន់ទន្លេមេគង្គ តាមរយៈការចូលរួមចំណែកក្នុងការតាក់តែង និងការអនុវត្តគោលនយោបាយដីធ្លីដែលសមស្រប។ គម្រោងឆ្លើយតបទៅនឹងអាទិភាពថ្នាក់ជាតិពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រការបង្កើនកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការគាំទ្រដល់កសិករខ្នាតតូចដើម្បីពួកគេអាចមានសន្តិសុខនិងអាចធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវស្តីពីការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី។ MRLG ប្រតិបត្តិការ នៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ចាប់តាំងពីខែមេសា ឆ្នាំ២០១៤ មកម្ល៉េះ។

សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង MRLG សូមស្វែងរកនៅលើគេហទំព័រ www.mrlg.org

គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេងមេគង្គ (MRLG) គឺជាគម្រោងមួយរបស់រដ្ឋាភិបាលប្រទេសស្វីស តាមរយៈទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) ដោយមានហិរញ្ញប្បទានបដិភាគពីក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (BMZ) និងរដ្ឋាភិបាលលុចហ្សំបួរ។

គម្រោង MRLG អនុវត្តដោយក្រុមហ៊ុន សមធម៌ដីធ្លីអន្តរជាតិ (Land Equity International) ហៅកាត់ថា LEI សហការជាមួយអង្គការ GRET អ្នកវិជ្ជាជីវៈដើម្បីការអភិវឌ្ឍដោយយុត្តិធម៌ និងគាំទ្រដោយអង្គការ GIZ។

គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ
បន្ទប់លេខ ១១ ផ្ទះលេខ ២៦២ Ban Saphanthong Kang, ស្រុក Sisattanak ក្រុងវៀងចន្ទ
សាធារណរដ្ឋប្រជាមានិតឡាវ
ប្រអប់សំបុត្រ ២៩៧៣ Vientiane Lao PDR 01000
ទូរស័ព្ទ៖ +856 21 454 807
អ៊ីម៉េល៖ mlrgcommunications@gmail.com

សេចក្តីប្រកាសមិនទទួលខុសត្រូវ៖

ទស្សនៈមតិយោបល់ និងការបកស្រាយនៅក្នុងឯកសារបោះពុម្ពផ្សាយនេះគឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ និងអ្នកផ្តល់វិភាគទាន។ ទស្សនៈ មិតយោបល់ និងការបកស្រាយទាំងនេះមិនឆ្លុះបញ្ចាំងពីទស្សនៈឬគោលគំហរផ្លូវការឬមិនផ្លូវការរបស់ **SDC, BMZ** និង លុចហ្សំបួរ ឡើយ។

ឧបត្ថម្ភមូលនិធិដោយ៖ អនុវត្តដោយ៖ គាំទ្រដោយ៖